# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Jul-2013, 12:58
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាបន្ថែមដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ

---

**ដាក់ដោយ:**

**មេធាវីការពារក្តី នួន ជា:**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSENSWEIG

Forest O’NEILL-GREENBERG

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ
Elisabeth SIMONNEAU-FORT

អនុលោមតាមវិធាន ១០៤(១), ១០៤(៤) និង ១០៥(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") សូមដាក់សារណាបន្ថែមនេះទៅលើសារណាតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២ ("សារណាតប")[1] ដូចខាងក្រោម៖

1. មេធាវីការពារក្តីដាក់សារណាបន្ថែមនេះទៅលើសារណាតបរបស់ខ្លួន ក្នុងគោលបំណងដាក់ជូនភស្តុតាងថ្មីដល់អង្គជំនុំជម្រះតុលាការកំពូល ដែលបង្ហាញពីចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធ្វើសេចក្តីសន្និដ្ឋានទៅលើអង្គហេតុក្នុងសំណុំរឿង ០០២/០១ ដោយផ្អែកលើភស្តុតាងដែលមេធាវីការពារក្តីពុំបានទទួលឱកាសក្នុងការឆ្លើយតបវិញ។ ចំណុចថ្មីៗដែលលើកយកមកបង្ហាញទាំងនេះផ្តល់ការគាំទ្រដែលមិនមានពីមុនដល់ការលើកឡើងរបស់មេធាវីការពារក្តីដែលថា ការបំបែកដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ក្នុងទម្រង់ដែលមាននៅក្នុងដំណើរការជំនុំជម្រះនេះ មិនស្របទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការជំទាស់ទៅនឹងភស្តុតាងដាក់បន្ទុករូបគាត់ និងសិទ្ធិទទួលបានសាលាក្តីមួយដែលឯករាជ្យ និងមិនលម្អៀងនោះទេ។

## I. ប្រវត្តិនីតិវិធី

2. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចជាថ្មីក្នុងការបំបែកដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[2]។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចនោះ ("បណ្តឹងសាទុក្ខ")[3] ហើយនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ បានដាក់សារណាបន្ថែមទៅលើបណ្តឹង

---

[1] ឯកសារលេខ **E284/4/4**, "សារណាតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២", ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ ("សារណាតប")។

[2] ឯកសារលេខ **E284**, "សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣", ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")។

[3] ឯកសារលេខ **E284/4/1**, "បណ្តឹងសាទុក្ខភ្លាមៗជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី", ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខ")។

សាទុក្ខនោះ[4]។ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបមួយ ហើយ នៅថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ មេធាវីការពារក្តីបានដាក់សារណាតបវិញ[5]។

3. ពាក់ព័ន្ធនឹងផលប៉ះពាល់នៃការបំបែកកិច្ចដំណើរការនីតិវិធីទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ នៅក្នុងបណ្តឹងសាទុក្ខ មេធាវីការពារក្តីបានលើកឡើងជាទឡ្ហីករណ៍ (មួយផ្នែក) ដូចខាងក្រោម៖

> បទពិសោធន៍នៃសវនាការសំណុំរឿង ០០២/០១ បានបង្ហាញថា ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយមានការពាក់ព័ន្ធគ្នាខ្លាំងពេក ដែលមិនអនុញ្ញាតឱ្យមានការបំបែកទៅជាការជំនុំជម្រះក្តីដាច់ដោយឡែកពីគ្នា។ កិច្ចប្រឹងប្រែងក្នុងការធ្វើដូច្នេះនៅក្នុងសំណុំរឿង ០០២/០១ បានបង្កឱ្យមានព្យសនកម្មទៅលើសិទ្ធិរបស់ នួន ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងធ្វើឱ្យមិនអាចគ្រប់គ្រងសំណុំរឿង ០០២/០១ បានផងដែរ។ ការជំនុំជម្រះក្តីជាវគ្គៗនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះតែមួយ នឹងកាន់តែរំលោភថែមទៀតទៅលើសច្ចធារណ៍នៃនិរទោស និងសិទ្ធិក្នុងការមានសាលាក្តីឯករាជ្យ និងមិនលម្អៀង។ មេធាវីការពាក្តីបានលើកការជំទាស់ទាំងអស់នេះ ចំពោះការបំបែកកិច្ចដំណើរការនីតិវិធីដែលបានសម្រេចសាជាថ្មី នៅក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។
>
> វិសាលភាពមានកម្រិតនៃសំណុំរឿង ០០២/០១ បានបង្កព្យសនកម្មដល់ នួន ជា យ៉ាងខ្លាំងជាទីបំផុត ដោយបានបង្អាក់លទ្ធភាពរបស់គាត់ក្នុងការលើកឡើងការពារខ្លួនឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ គោលនយោបាយទាំងឡាយដែល នួន ជា ត្រូវបានចោទប្រកាន់ថាអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ គឺជា "ផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងខ្លាំងជាងគេ ក្នុងការរៀបចំសណ្តាប់ធ្នាប់ឡើងវិញចំពោះប្រទេសមួយ និងសេដ្ឋកិច្ចមួយដែលរងនូវការបំផ្លិចបំផ្លាញ

---

4 ឯកសារលេខ E284/4/2, "សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី" ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងឧទ្ធរណ៍បន្ថែម")។

5 ឯកសារលេខ E284/4/3, "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា", ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ ("ចម្លើយតប")។

ដោយសារសង្គ្រាម និងនាំមកនូវឯករាជភាពចំពោះប្រជាជនដែលស្ថិតក្រោមវិធាននៃការត្រួតត្រា និងអំណាចអាណានិគមបរទេស អស់រយៈពេលជាច្រើនឆ្នាំ"។ ដើម្បីធ្វើការវាយតម្លៃលើចេតនារបស់ នួន ជា ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ ដែលជាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវបានស្នើសុំឱ្យធ្វើការសម្រេចថាអ្វីដែល នួន ជា សង្ឃឹមទុកថានឹងកើតចេញពីគោលនយោបាយទាំងអស់នោះ។ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ផែនការនោះ "មិនបានបញ្ចប់នៅត្រឹមគោលដៅរបស់អ្នកដែលត្រូវបានជម្លៀសនោះទេ"។ ហេតុនេះត្រូវតែធ្វើការពិចារណាទៅលើផែនការនេះទាំងមូលតែម្តង។

ទស្សនៈទូលំទូលាយនេះមិនមានចំពោះ នួន ជា នៅក្នុងក្របខណ្ឌចង្អៀតនៃសំណុំរឿង ០០២/០១ នេះទេ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូង ទាំងសហព្រះរាជអាជ្ញាលើកឡើងថា គោលនយោបាយដែលបានលើកឡើងទាំងប្រាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវមានការសួរដេញដោលដោយភាគីនានា កំណត់ហេតុបង្ហាញច្បាស់លាស់ថា លើកលែងតែសាក្សីដែលត្រូវបានជ្រើសរើសមុនជាក់លាក់ការសួរដេញដោលផ្ទាល់តែងតែត្រូវបានកម្រិតត្រឹមតែប្រធានបទដែលស្ថិតក្រោមវិសាលភាពនៃសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ។ ដោយសារតែអង្គហេតុនានាដែលហួសពីវិសាលភាពនោះ មានការទាក់ទិនទៅនឹងមេធាវីការពារក្តីរបស់ នួន ជា ការបំបែកកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី មិនមានលក្ខណៈសមស្របទេ។

[...]

ការលំបាកដូចគ្នានៅក្នុងការកំណត់លើផ្នែកនីមួយៗដាច់ពីគ្នានៅក្នុងដីកាដំណោះស្រាយ ក៏បណ្តាលឱ្យមានការបន្តរំលោភលើលទ្ធភាពរបស់ នួន ជា ក្នុងការតទល់ជាមួយនឹងសាក្សីដាក់បន្ទុកលើខ្លួនផងដែរ។ ផ្នែកដ៏សំខាន់មួយនៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០១ មានការពាក់ព័ន្ធទៅនឹងបញ្ហានៃការអនុវត្តជាទូទៅលើសំណុំរឿង ០០២ ទាំងមូល ដូចជា សាវតារប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធយោធា រដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនានា។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សេរីភាពច្រើនដល់សហព្រះរាជអាជ្ញា ដើម្បីជជីកសួរសំណួរទាំងឡាយដែលនៅក្រៅ

វិសាលភាពនៃសំណុំរឿង ០០២/០១ រួមទាំងមន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាននានា ក្រោមរូបភាពនៃការទាញយកសក្ខីកម្មនានាពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធ"។

ការដេញដោលលម្អិតលើភស្តុតាងទាំងនោះ អាចស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដូចជាការប្រើប្រាស់យុទ្ធសាស្ត្រមិនល្អមួយនៃពេលវេលាដែលបានលៃទុកសម្រាប់ក្រុមមេធាវីការពារក្តី ដែលពេលវេលានេះមានតិចតួចណាស់។ ទោះជាយ៉ាងណាក្តី ភស្តុតាងនោះមាននៅក្នុងសំណុំរឿង និងនៅចំពោះមុខអង្គជំនុំជម្រះ។ ប្រសិនបើភស្តុតាងទាំងនោះអាចទទួលយកបាននៅក្នុងសំណុំរឿង ០០២/០២ វានឹងធ្វើឲ្យមានរំលោភលើសិទ្ធិរបស់ នួន ជា នៅក្នុងការតទល់ជាមួយនឹងសាក្សីដាក់បន្ទុកលើខ្លួន។ បើមិនដូច្នោះទេ សាក្សីទាំងអស់នោះចាំបាច់ត្រូវបានកោះហៅមក ដែលនឹងធ្វើឲ្យខូចខាតដល់គោលបំណងនៃការបំបែកកិច្ចដំណើរការនីតិវិធី ហើយវានឹងបង្កើតជាសំអាងហេតុក្នុងការជំនុំជម្រះតាមដីកាដំណោះស្រាយទាំងមូលតែម្តង[6]។

4. នៅក្នុងចម្លើយតបរបស់ខ្លួនដែលបានដាក់នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ការចោទប្រកាន់នេះ "ពុំមានមូលដ្ឋានទេ"៖

មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យតាំងសំណួរចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីគ្រប់រូបដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ នៅក្នុងសំណុំរឿង ០០២/០១។ មានការបញ្ជាក់យ៉ាងច្បាស់លាស់តាំងពីដំបូងហើយថា ការបន្ថែមពីលើព្រឹត្តិការណ៍នៃឧក្រិដ្ឋកម្មសំខាន់ៗ ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ វិសាលភាពនៃសំណុំរឿង ០០២/០១ បានដាក់បញ្ចូលប្រវត្តិដើម និងរចនាសម្ព័ន្ធរដ្ឋបាល ការប្រាស្រ័យទាក់ទង និងយោធា និងថាគ្រប់ភាគីទាំងអស់អាចដាក់ភស្តុតាង និងសួរសំណួរសាក្សីលើវិស័យទាំងនេះបាន[7]។

## II. ការសម្រេចលើភស្តុតាងពីមុនៗ ក្នុងសំណុំរឿង ០០២/០១

---

6 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១២ ដល់ ១៤, ១៨ ដល់ ១៩។

7 ចម្លើយតប, កថាខណ្ឌ ៩។

5. ក្របខណ្ឌពីដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការបំបែកកិច្ចដំណើរការនីតិវិធីបានកំណត់ភាពខុសគ្នារវាង "អត្ថិភាព" នៃគោលនយោបាយទាំងប្រាំនៃសហឧក្រិដ្ឋកម្មរួម និង "ការអនុវត្ត" គោលនយោបាយទាំងនោះ។ អង្គជំនុំជម្រះបានសម្រេចថា ទោះបីជា "អត្ថិភាព" នៃគោលនយោបាយទាំងប្រាំគឺជាបញ្ហា ដែលត្រូវដោះស្រាយក្នុងសំណុំរឿង ០០២/០១ ក៏ដោយ ក៏ការពិចារណាលម្អិតអំពីអង្គហេតុនៅក្នុងសវនាការដំណាក់កាលដំបូងនឹងត្រូវបានបម្រុងទុកសម្រាប់ប្រធានបទនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[8]។ អង្គជំនុំជម្រះបានភ្ជាប់ "ឧបសម្ព័ន្ធ" មួយ ក្នុងគោលបំណងផ្តាច់កថាខណ្ឌទាំងនោះដែលជាបញ្ហាត្រូវដោះស្រាយនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២/០១ ចេញពីកថាខណ្ឌនានាដែលត្រូវដោះស្រាយ[9]។ បើតាមឧបសម្ព័ន្ធនោះ ការចោទប្រកាន់នានាដែលជាបញ្ហាត្រូវដោះស្រាយពាក់ព័ន្ធនឹងគោលនយោបាយសហឧក្រិដ្ឋកម្មរួមដែលនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ មានតែនៅក្នុងកថាខណ្ឌ ១៥៦ ដល់ ១៥៩ នៃដីកាដំណោះស្រាយតែប៉ុណ្ណោះ[10]។ កថាខណ្ឌទាំងនោះលើកឡើងពីគោលបំណងរួម កំណត់ឈ្មោះគោលនយោបាយទាំងប្រាំ និងបញ្ចូលជើងទំព័រមួយ។ ការចោទប្រកាន់ទាំងអស់ពាក់ព័ន្ធនឹងគោលនយោបាយទាំងនេះ ដែលត្រូវបានដកចេញពីសំណុំរឿង ០០២/០១ រួមមាន៖ (i) ចំណុចពិស្តារ ***ទាំងអស់*** អំពីគោលនយោបាយទាំងនោះ រួមទាំង (ក្នុងចំណោមចំណុចផ្សេងទៀត) កាលបរិច្ឆេទ គោលបំណង មាតិកា និងលក្ខណៈនៃការបង្កើត[11]; (ii) ការចោទប្រកាន់ពីមូលដ្ឋានឧក្រិដ្ឋកម្ម ***មួយចំនួន*** [12]; និង (iii) ការចោទប្រកាន់ ***ផ្សេងៗ*** ពីការចូលរួមរបស់ជនជាប់ចោទ[13]។

---

[8] ឯកសារលេខ **E-124/7** "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានាព្រមទាំងឧបសម្ព័ន្ធ" ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ កថាខណ្ឌ ១១។

[9] ឯកសារលេខ E124/7.3, "ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ (E163)", ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ("ឧបសម្ព័ន្ធនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី") ចំណុច 1(vi), (vii)។

[10] ឧបសម្ព័ន្ធនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ចំណុច1(vi)។

[11] ឧបសម្ព័ន្ធនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ចំណុច 1(vii); ឯកសារលេខ D427, "ដីកាដំណោះស្រាយ", ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ១៦៨ ដល់ ១៧៧ (ពោលគឺពាក់ព័ន្ធសហករណ៍ និង ការដ្ឋាន)។

[12] ឧបសម្ព័ន្ធនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ចំណុច 1(vii)។

6. ដើម្បីផ្តល់សុពលភាពដល់ការបែងចែកភាពខុសគ្នារវាងអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម និងការអនុវត្តគោលនយោបាយទាំងនោះ អង្គជំនុំជម្រះបានណែនាំដល់ភាគីថា ជាទូទៅ ពួកគេមានសិទ្ធិពិនិត្យទៅលើសាក្សីអង្គហេតុតែចំពោះចំណុចណាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ មានតែសាក្សីជំនាញប៉ុណ្ណោះ (ពីររូបក្នុងចំណោមនោះបានចូលរួមនៅចំពោះមុខអង្គជំនុំជម្រះ) ដែលជាកម្មវត្ថុនៃការសួរដេញដោលពាក់ព័ន្ធនឹងដីកាដំណោះស្រាយទាំងមូល[14]។ លើសពីនេះទៀត ភាគីមានសិទ្ធិសួរសំណួរសាក្សីលើអង្គហេតុក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ដែលចាំបាច់ដើម្បីកំណត់ទៅលើបញ្ហារចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនង ឬ យោធា[15]។ ការសួរសំណួរផ្សេងទៀតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវហាមឃាត់[16]។

7. ដោយគិតដល់វិធានទាំងនេះ មេធាវីការពារក្តីបានជំទាស់ទៅនឹងការទទួលយកភស្តុតាងជាឯកសារហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១ ទៅទៀត[17]។ អង្គជំនុំជម្រះបានបដិសេធការជំទាស់ទាំងនោះដោយផ្អែកលើមូលដ្ឋានថា ការជំទាស់ទាំងនោះមិនបានបង្ហាញពីភាពជាក់លាក់ឲ្យបានពេញលេញឡើយ និងការ

---

13 ឧបសម្ព័ន្ធនៃការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ចំណុច1(vii); ដីកាដំណោះស្រាយ, កថាខណ្ឌ ៩០៣ ដល់ ៩១៥ (ពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាន)។

14 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៤ និង ជើងទំព័រ ៣៤។

15 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៤ និង ជើងទំព័រ ៣៤។

16 បណ្តឹងសាទុក្ខ, កថាខណ្ឌ ១៤ និង ជើងទំព័រ ៣៤។

17 សូមមើលឯកសារលេខ **E-131/1/9** “ការជំទាស់ ការកត់សម្គាល់ និង ការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗ ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង” ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១១, កថាខណ្ឌ ១០, ២០។ ឯកសារលេខ **E-131/1/12** “ការជំទាស់ទៅនឹងឯកសារ និង សារណាបន្ថែមដោយអនុលោមតាមវិធាន ៩២” ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ កថាខណ្ឌ ១ និង ជើងទំព័រ ១។ ឯកសារលេខ **E-131/1/10** “ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង”, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២ (*សូមមើល* ការជំទាស់នានានៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ *ឧទា.* ឧបសម្ព័ន្ធ ៨៖ កំណត់ហេតុពីស្រុកត្រាំកក់)។ ឯកសារលេខ **E-131/1/7** “ការជំទាស់របស់ក្រុមមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ទៅនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវប្រើប្រាស់ក្នុងអំឡុងពេលសវនាការដំណាក់កាលដំបូង” ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ កថាខណ្ឌ ១២។ ឯកសារលេខ **E-223/2/8** “ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិក” ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ១៧ ដល់ ៣៣។

លើកឡើងដោយប្រាកដថា រាល់ឯកសារទាំងអស់ "ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/០១[18]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបានទទួលយកឯកសារទាំងនោះ តែមិនបានពន្យល់ពីតួនាទី និងភាពពាក់ព័ន្ធរបស់ឯកសារទាំងនោះ ទៅលើបញ្ហាដែលត្រូវដោះស្រាយក្នុងសំណុំរឿង ០០២/០១ ទេ។ អង្គជំនុំជម្រះក៏បានបង្ហាញជាលើកដំបូងផងដែរកាលពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ថា ខ្លួនមានបំណងទទួលយកចម្លើយសាក្សីចំនួន ១.៥០០ ដែលពុំមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ[19]។ ចម្លើយទាំងនោះចំនួនរាប់រយពាក់ព័ន្ធនឹងបញ្ហាអង្គហេតុហួសពីវិសាលភាពនៃសំណុំរឿង ០០២/០១[20]។ រយៈពេលជាច្រើនសប្តាហ៍មុនពេលសវនាការបានបញ្ចប់ទៅ អង្គជំនុំជម្រះមិនទាន់បានចេញសេចក្តីសម្រេចណាមួយដែលមានសំអាងហេតុ ដែលពន្យល់ពីភាពពាក់ព័ន្ធនៃភស្តុតាងទាំងនោះ ទៅនឹងការចោទប្រកាន់នានាដែលត្រូវដោះស្រាយក្នុងសំណុំរឿង ០០២/០១ នោះទេ។

## III. សវនាការដេញដោលលើឯកសារ

8. ក្នុងសប្តាហ៍ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងចាប់ផ្តើមសវនាការបង្ហាញឯកសាររបស់ខ្លួនជាចុងក្រោយក្នុងសំណុំរឿង ០០២/០១ ដែលពាក់ព័ន្ធនឹងគោលនយោបាយចំនួនប្រាំនៃសហឧក្រិដ្ឋកម្មរួម ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ និង តួនាទីរបស់ នួន ជា។ នៅ ពេលដែលសហព្រះរាជអាជ្ញាធ្វើបទបង្ហាញពីសុន្ទរកថាមួយដែលអះអាងថាត្រូវបានថ្លែងដោយ ប៉ុល ពត ពាក់ព័ន្ធនឹងគោលនយោបាយសហករណ៍ និងការដ្ឋាន ហើយត្រូវបានបោះពុម្ពផ្សាយឡើងវិញនៅក្នុងទស្សនាវដ្តី

---

[18] ឯកសារលេខ **E185**, "សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរវគ្គដំបូងនៃសំណុំរឿង ០០២/០១", ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ១៥(X), ២៣; ឯកសារលេខ **E185/1**, សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត", ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២, កថាខណ្ឌ ៥(i), ១២។

[19] ឯកសារលេខ **E1/207.1**, "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ", ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ២៦:៣ដល់ ១២ (ភាសាអង់គ្លេស)។

[20] ឯកសារលេខ **E278.2**, "ទិដ្ឋភាពទូទៅនៃឧបសម្ព័ន្ធ ១២ និង ១៣ ដែលត្រូវបានកែប្រែ" (ភាសាអង់គ្លេស), ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣; ឯកសារលេខ **E223/2/7.2**, "ឧបសម្ព័ន្ធ ១ សម្ងាត់៖ ចម្លើយជាលាយលក្ខណ៍អក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានផ្តល់ភស្តុតាងផ្ទាល់មាត់", ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៣។

ទង់បដិវត្តន៍នោះ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ថា ឯកសារនោះនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១។ ចៅក្រម Lavergne បានប្រកាសពីការសម្រេចរបស់អង្គជំនុំជម្រះដូចតទៅ៖

> អង្គជំនុំជម្រះយល់ឃើញថា ឯកសារដែលបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញានោះគឺពាក់ព័ន្ធទៅនឹងសេចក្តីណែនាំដែលត្រូវអនុវត្តនៅក្នុងក្របខណ្ឌគោលនយោបាយសហករណ៍ ហើយសេចក្តីណែនាំនោះត្រូវបានធ្វើឡើងដោយបដ្ឋិមបក្ស ដូច្នេះនេះមិនមែនជាការអនុវត្តន៍នៅតាមមូលដ្ឋាននោះទេ។ ហើយការអនុវត្តនៅមូលដ្ឋាននោះ គឺវាមិនត្រូវស្ថិតនៅក្នុងឯកសារគន្លឹះនៃការបង្ហាញឯកសារនៅក្នុងសវនាការនោះទេ[21]។ (គូសបញ្ជាក់បន្ថែម)

9. នៅថ្ងៃបន្ទាប់ មុនពេលដែលដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្លួនពាក់ព័ន្ធនឹងគោលនយោបាយសហករណ៍ មេធាវីការពារក្តី ខៀវ សំផន បានជំទាស់ម្តងទៀតថា ឯកសារដែលសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានបំណងយកមកបង្ហាញនោះ ភាគច្រើនជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានពណ៌នាពី “ការអនុវត្តន៍គោលនយោបាយនៅមូលដ្ឋាន”[22]។ មេធាវីការពារក្តី នួន ជា បានគាំទ្រការជំទាស់នេះ[23]។ សហព្រះរាជអាជ្ញាបានឆ្លើយតបដូចខាងក្រោម៖

> ខ្ញុំគិតថាក្នុងសវនាការនេះ យើងដឹងច្បាស់ណាស់ថា យើងបង្ហាញ អំពីឯកសារដែលពាក់ព័ន្ធទៅនឹងអត្ថិភាពនៃគោលនយោបាយ គឺថាខ្ញុំត្រូវតែនិយាយឡើយវិញ គឺថាជាគោលនយោបាយដែលផ្សព្វផ្សាយ មិនផ្សព្វផ្សាយទៅដល់មូលដ្ឋានទេ គឺថាវាជាគោលនយោបាយជាលក្ខណៈទ្រឹស្តីដែលបង្កើតឡើងដោយមេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ ក៏ប៉ុន្តែត្រង់ចំណុចនេះ គឺថាអង្គជំនុំជម្រះមិនចង់បាននោះទេ អ្វីដែលយើងចង់បាននោះគឺថា ជាសេចក្តីណែនាំដែលត្រូវបានធ្វើឡើងនិងផ្សព្វផ្សាយដែលត្រូវតែអនុវត្ត។
>
> ទី២ គោលនយោបាយដែលមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញអ៊ីចឹង គឺថាមិនមានកាលបរិច្ឆេទច្បាស់លាស់ទេ គឺថាមានការវិវត្តន៍ទៅមុខ

---

[21] សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ៩:២០ ដល់ ១០:១២ (ភាសាអង់គ្លេស)។

[22] សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ៣៥:៤ ដល់ ៥ (ភាសាអង់គ្លេស)។

[23] សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ៣៥:២២ ដល់ ៣៦:៣, ៤៦:១៧ ដល់ ៤៧:២២។

ហើយជួនកាលទៅ មានសេចក្តីលម្អិតដែលមិនមានគ្រោងនៅពេលដំបូងនោះទេ ដោយសារតែវាមានការវិវត្តន៍។ ដូច្នេះមានសេចក្តីណែនាំបន្ថែមពាក់ព័ន្ធទៅនឹងគោលនយោបាយដែលបានបង្កើតឡើងពីដំបូង ដែលបានបញ្ជូនទៅកាន់មូលដ្ឋាន។ ហេតុអ្វីបានជាមានការវិវត្តន៍នៃគោលនយោបាយ ពីព្រោះថាវាមានភាពទាក់ទងគ្នាទៅវិញទៅមករវាងមេដឹកនាំមជ្ឈិមបក្ស និងទំនាក់ទំនង -- និងរបាយការណ៍ដែលចេញមកអំពីមូលដ្ឋាន។ របាយការណ៍នេះពាក់ព័ន្ធនឹងការអនុវត្ត ក៏ប៉ុន្តែវាជួយឲ្យមានការអនុវត្តគោលនយោបាយ ហើយនិងឲ្យមានចំណុចរបត់ផ្សេងទៀត។ ដូច្នេះចំពោះខ្ញុំ វាមានការទាក់ទងគ្នាទៅវិញទៅមកទាំងស្រុករវាងគោលនយោបាយផ្ទាល់ និងការអនុវត្តគោលនយោបាយគោលនយោបាយទាំងអស់នោះ។ ហើយការអនុវត្តគោលនយោបាយទាំងអស់ វាអាចឲ្យគោលនយោបាយទាំងអស់នោះមានការអភិវឌ្ឍ។ នេះគឺជាគោលនយោបាយដែលមានលក្ខណៈជាក់ស្តែង។ អត្ថិភាពនៃគោលនយោបាយទាំងអស់នេះអាចមានលក្ខណៈផ្សេងគ្នា ខ្ញុំនិយាយតែពីអត្ថិភាពទេ ខ្ញុំមិននិយាយពីការវិវត្ត ការអនុវត្តនោះទេ ដូចឯកសារមជ្ឈិមបក្សបានបង្ហាញអ៊ីចឹង គឺថាយើងឃើញថាមានសេចក្តីណែនាំជាផ្លូវការរបស់បក្សដែលមានបង្ហាញនៅក្នុងទង់បដិវត្តន៍ នៅក្នុងកំណត់ហេតុកិច្ចប្រជុំ នៅក្នុងរបាយការណ៍ នៅក្នុងទូរលេខ នៅក្នុងសេចក្តីប្រកាសរបស់មេដឹកនាំ នៅក្នុងសុន្ទរកថា ដើម្បីបង្ហាញថាពិតជាមានគោលនយោបាយមែន ហើយពិតជាមានការផ្សព្វផ្សាយមែន ហើយគោលនយោបាយទាំងអស់នោះត្រូវតែអនុវត្តជាដាច់ខាត។ ដូច្នេះយើងមិនមែនបង្ហាញពីគោលនយោបាយពីខាងលើទេ គឺជាការអនុវត្តពីថ្នាក់ក្រោម។ ហើយសេចក្តីសម្រេចរបស់តុលាការអន្តរជាតិនោះអាចទទួលយកបានថា វាអាចកម្រិតត្រឹមអាកប្បកិរិយាដែលមានលក្ខណៈដូចគ្នា ហើយនិងអនុវត្តជាទូទៅនៅតាមមូលដ្ឋានដែលបង្ហាញថា ពិតជាមានគោលនយោបាយនៅថ្នាក់ជាតិមែន ដើម្បីឲ្យអនុវត្តនៅគ្រប់កន្លែងទាំងអស់នៅក្នុងពេលតែមួយ ដែលមានការផ្សព្វផ្សាយទៅដល់បុគ្គល។

មានការ មានសេចក្តីសម្រេចរបស់ គូនរៈ ដែលជាការប្តឹងឧទ្ធរណ៍នៅចំពោះមុខតុលាការសម្រាប់អតីតយូហ្គូស្លាវី គឺកថាខណ្ឌ៩៨ ហើយក៏មានសេចក្តីសម្រេចរបស់ ប្រាកូស៊ីវីក គឺសាលក្រមរបស់សាលាដំបូង គឺកថាខណ្ឌ៧២ -- ៧២១ (សូមទោស)។ ខ្ញុំមិនមានអត្ថបទជាភាសាបារាំងនៅចំពោះមុខទេ៖ "អង្គជំនុំជម្រះយល់រកឃើញថាភស្តុតាងនៃការប្រព្រឹត្តរួមគ្នាក្នុងការសម្លាប់រង្គាលតាមរយៈការចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ព្រមទាំងកម្ទេចទៅលើមនុស្ស

ដែលជាជនជាតិមូស្លីម ឬស្មៀរជាង ៧០០០នាក់។ ហើយវត្តមាននៃផែនការទាំងអស់នេះក្នុងការសម្លាប់ប្រជាជនទាំងបុរសស្ត្រី ជាង ៧០០០នាក់នោះគឺគ្រោងធ្វើឡើងក្នុងរយៈពេលត្រឹមតែ ៥ថ្ងៃ។ ដូច្នេះហើយផែនការនេះគឺមិនអាចធ្វើទៅបានទេ ប្រសិនបើគ្មានការរួមសហការពីសមាជិកដែលជាសហឧក្រិដ្ឋកម្មរួម"។ ដូច្នេះនេះដើម្បីផ្តល់ឧទាហរណ៍ជាភស្តុតាងជូនអង្គជំនុំជម្រះដែលបង្ហាញអំពីការពិតនៅថ្នាក់មូលដ្ឋាន។

លក្ខណៈទីបី ដែលយើងអាចបង្ហាញអំពីអត្ថិភាពនៃគោលនយោបាយនេះបានគឺថា គឺរួមផ្សំគ្នាថា មានគោលនយោបាយនៅក្នុងឯកសាររបស់ មជ្ឈិមបក្សដែលបង្កើតគោលនយោបាយដើម្បីឲ្យយើងសន្និដ្ឋានថាមានគោលនយោបាយនៅក្នុងសុន្ទរកថានៅក្នុងឯកសាររបស់បក្សនានា ហើយនិង<u>ដើម្បីបង្ហាញគោលនយោបាយទាំងអស់នេះតាមរយៈ ការដែលថាមាននៅក្នុងមូលដ្ឋានហើយនឹងត្រូវបានអនុវត្តជាទូទៅនៅគ្រប់កន្លែង</u>[24]។ (គូសបញ្ជាក់បន្ថែម)

10. មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបវិញយ៉ាងដូច្នេះថា៖

លោកប្រធាន នេះជាអ្វីដែលខ្ញុំព្យាយាមជំទាស់ហើយ ព្យាយាមចៀសវាងហើយនៅពេលដែលខ្ញុំជំទាស់កាលពីម្សិលមិញនិងម្សិលម៉្ងៃនោះ គឺថាយើងងាកចេញយ៉ាងប៉ិនប្រសព្វទៅកាន់សវនាការផ្សេងទៀតហើយ។ នេះគឺជាចំណុចច្បាស់លាស់ណាស់។

[...]

យើងតែងតែនិយាយជានិច្ចនៅចំពោះមុខអង្គជំនុំជម្រះថា កង្វល់របស់យើងតែមួយគត់នោះគឺថា គឺយើងអាចការពារកូនក្តីរបស់យើងឲ្យបានត្រឹមត្រូវ ដោយដឹងច្បាស់ថា ទោះជានៅក្នុងសំណុំរឿង ០០២/០១ ឬក៏សំណុំរឿងបន្តបន្ទាប់ទៀត នោះយើងដឹងថា តើយើងត្រូវឆ្លើយតបទៅនឹងអ្វីឲ្យបានច្បាស់លាស់។

ដូច្នេះជាក់ស្តែងនៅថ្ងៃនេះ អ្វីដែលសហព្រះរាជអាជ្ញា ហើយនិងតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិយាយនោះគឺថា យើងមិនអាចនិយាយអំពីគោលនយោបាយបីផ្សេងទៀតដែលមិនពាក់ព័ន្ធនឹង

[24] សេចក្តីព្រាងប្រតិចារិក, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ៤០:៨ ដល់ ៤២:២៥ (ភាសាអង់គ្លេស)។

សំណុំរឿង ០០២/០១ នេះ ដោយមិននិយាយអំពីការអនុវត្តនៅតាមមូលដ្ឋាននោះទេ។ អ៊ីចឹង តាមផ្លូវច្បាប់ តើមានន័យយ៉ាងម៉េចអ្វីដែលពួកគាត់បានលើកឡើងនោះ? មានន័យថា អង្គជំនុំជម្រះអនុញ្ញាតឲ្យមានការបង្ហាញឯកសារបន្តស្តីអំពីគោលនយោបាយ ដែលវាមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង ០០២/០១ នោះមានន័យថាភស្តុតាងមួយចំនួនមិនត្រូវស្ថិតនៅក្នុងកម្មវត្ថុនៃសំណុំរឿង ០០២/០១ នេះដោយមិនដាក់ឲ្យអង្គជំនុំជម្រះវាយតម្លៃ។ ដូច្នេះចំពោះយើង យើងមិនមានភស្តុតាងតាមរយៈសាក្សីដែលមកផ្តល់សក្ខីកម្ម យើងមិនអាចចោទសួរពួកគាត់បានអំពីចំណុចទាំងអស់នេះទេ។ គឺថាពេលដែលមកនោះយើងមិនអាចពង្រីកទៅលើចំណុចទាំងអស់ហ្នឹងទេ។ ហើយនៅក្នុងសារណាបញ្ចប់របស់យើងក៏យើងមិនអាចនិយាយទៅដល់ គោលនយោបាយដែលមិនពាក់ព័ន្ធនឹងសវនាការរបស់យើងនេះដែរ។

បញ្ហានៅចំពោះមុខយើងទាំងអស់គ្នានៅថ្ងៃនេះគឺថា តើឲ្យខ្ញុំការពារកូនក្តីការពារជនជាប់ចោទយ៉ាងម៉េចកើត ប្រសិនបើយើងត្រូវឆ្លើយទៅនឹងបញ្ហាដែលកំណត់ដោយអង្គជំនុំជម្រះផង ហើយនិងកំណត់ដោយសវនាការផ្សេងផង។ ដូច្នេះខ្ញុំគិតថា ការដែលខ្ញុំធ្វើការជំទាស់បែបនេះ គឺថាដើម្បីចៀសវាងកុំឲ្យមានបញ្ហា ពីព្រោះថានៅក្នុងសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី។

[...]

សម្រាប់ជាគោលបំណងនៃសុច្ចរិតភាពតាមផ្លូវច្បាប់ យើងគួរតែផ្តោតទៅលើអ្វីដែលគួរមាននៅក្នុងសវនាការដំណាក់កាលនោះ និងមិនមែនអ្វីដែលមានក្នុងសវនាការដំណាក់កាលក្រោយៗទៀតទេ។ ប្រសិនបើយើងពិភាក្សាលើបញ្ហានានាដែលមិនពាក់ព័ន្ធ ទាក់ទិននឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះនោះ តើយើងនឹងពិភាក្សាបញ្ហាដដែលនេះនៅក្នុងសវនាការដំណាក់កាលបន្តបន្ទាប់បានយ៉ាងដូចម្តេច? នេះជាបញ្ហាផ្លូវច្បាប់ធ្ងន់ធ្ងរ ហើយមានសារៈសំខាន់ណាស់សម្រាប់បញ្ហានោះ ហើយ ដូច្នេះយើងឃើញហើយថា សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីគាត់បង្ហាញឯកសារខុសពីអ្វីដែលយើងបានកំណត់។ គាត់បានបញ្ជាក់ថា គាត់បានបង្ហាញអំពីការអនុវត្ត និងអំពីអាទិភាពដោយសារតែវាជាប់ពាក់ព័ន្ធគ្នា ដូច្នេះ ខ្ញុំគិតថាអ្វីដែលគាត់លើកឡើងនេះ គឺថាយើងត្រូវតែ ពិភាក្សាគ្នានៅក្នុងសវនាការ នៅក្នុង

ការជំនុំជម្រះក្តីលើកក្រោយទៀតនោះទេ។ ព្រោះថាវាខុសពីអ្វីដែលយើងបានកំណត់ជាមុនហើយ។ បើអញ្ចឹង តែការចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីមានគោលបំណងអ្វី ប្រសិនបើវាមិនត្រូវបានយកទៅអនុវត្តតាមនោះ?

វាជាបញ្ហាធ្ងន់ធ្ងរតាមផ្លូវច្បាប់ ហើយវាមានសារៈសំខាន់ខ្លាំងណាស់ ហើយជាថ្មីម្តងទៀត ខ្ញុំសូមឱ្យអង្គជំនុំជម្រះគិតពិចារណាទៅលើនេះជាចំណុចដែលយើងកំណត់នៅក្នុងសំណុំរឿងរបស់យើង។ យើងមិនបានប្តឹងសាទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកមុនរបស់អង្គជំនុំជម្រះទេ ហើយសូមរំឭកថា នៅពេលដែលអង្គជំនុំជម្រះផ្តល់ជូនវេទិកាទៅដល់សហមេធាវីការពារក្តី ខៀវ សំផន នេះ គឺថាយើងចង់ដឹងថា តើយើងត្រូវឆ្លើយតបទៅនឹងអ្វីឱ្យបានពិតប្រាកដ?

ប្រសិនបើមានការងាកចេញទៅរកគោលនយោបាយផ្សេងទៀតនោះ។ យើងគិតថា ការជំនុំជម្រះក្តីនេះមិនយុត្តិធម៌ទេ។ យើងមិនអាចឆ្លើយតបបានទេ។ ដូច្នេះ សិទ្ធិរបស់ជនជាប់ចោទនោះ ត្រូវដឹងថា តើត្រូវឆ្លើយទៅនឹងអ្វី? ដូច្នេះនៅពេលដែលមានការងាកចេញពីគោលនយោបាយមួយទៅគោលនយោបាយមួយផ្សេងទៀតបែបនេះហ្នឹង គឺថាយើងពិបាកធ្វើការណាស់។ អ៊ីចឹងការជំនុំជម្រះក្តីយើងនេះ គឺមិនមានយុត្តិធម៌ទេ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ដដែលថា យើងមិនអាចឱ្យមានការងាកចេញបែបនេះទេ។ បើសិនជាងាកចេញបែបនេះនោះ ការសម្រេចស្តីពីការបំបែកនីតិវិធីនោះ គ្មានន័យ គ្មានខ្លឹមសារអ្វីទេ[25]។

11. មេធាវីការពារក្តី នួន ជា បានយល់ស្របដោយបានលើកឡើងបន្ថែមថា៖

លោកប្រធាន ដើម្បីជាប្រតិចារឹក យើងខ្ញុំឯកភាពទាំងស្រុងជាមួយនឹងការសង្កេតលើកឡើងដោយក្រុមមេធាវីការពារក្តី ខៀវ សំផន។ ថ្ងៃនេះ និងថ្ងៃម្សិលមិញ យើងមិនមែន កំពុងលើកឡើងអំពីគោលនយោបាយនោះទេ។ យើងកំពុងលើកឡើងអំពីគោលនយោបាយសហឧក្រិដ្ឋកម្មរួម គោលនយោបាយឧក្រិដ្ឋ។ ហើយដូចខ្ញុំបានលើកឡើងពីមុនរួចហើយ នៅក្នុងវគ្គសវនាការនេះ កូនក្តីរបស់យើងខ្ញុំពុំមែនត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងការរៀបការ

25 សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ ៤៣:៩ ដល់ ៤៦:១៤ (ភាសាអង់គ្លេស)។

ដោយបង្ខំនោះទេ ពោលគឺ ការអនុវត្តគោលនយោបាយមួយក្នុងចំណោមគោលនយោបាយទាំង ៥ ដែលពុំមែនជាបញ្ហាចំបង នៅក្នុងពេលបច្ចុប្បន្ន។

ដូច្នេះ តាមការលើកឡើងរបស់មិត្តភ័ក្រដែលមានចំណេះដឹងជ្រៅជ្រះរបស់យើងខ្ញុំ យើងមានបញ្ហាធំមួយ ប្រសិនបើ នាពេលនេះ យើងផ្តោយលើកឡើងគោលនយោបាយទាំង ៣ ដែលនៅ សេសសល់ដោយពុំមានលទ្ធភាពសមស្របក្នុងការការពារខ្លួនប្រឆាំងនឹងគោលនយោបាយទាំងនេះ។

ដូច្នេះ ជាថ្មីម្តងទៀត យើងយល់អំពីផលវិបាកកើតចេញពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលថា គោលនយោបាយទាំងពីរដែលគួសបញ្ជាក់ពីឧក្រិដ្ឋកម្មទាំងឡាយដែលយើងកំពុងលើកឡើងនេះ អាចលើកយកមកពិភាក្សាបាន ពោលគឺគោលនយោបាយចំបងពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ។ អញ្ចឹងហើយបានជាយើងមិនបានជំទាស់ទៅនឹងការកំណត់គោលដៅទៅលើមន្ត្រីរបប លន់ នល់ ជាឧទាហរណ៍ ពីព្រោះនោះគឺជាគោលនយោបាយដែលគួសបញ្ជាក់ពាក់ព័ន្ធនឹង ទួលពោធិ៍ជ្រៃ។ ប៉ុន្តែ ប្រសិនបើពេលនេះ យើងលើកឡើងអំពីការរៀបការដោយបង្ខំ នោះវានឹងបង្កើតបញ្ហាធំនៅក្នុងសំណុំរឿង 00២/0២ ពីព្រោះថាប្រសិនបើយើងបង្ហាញឲ្យឃើញអំពីគោលនយោបាយសហឧក្រិដ្ឋកម្មរួម ជាឧទាហរណ៍ ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ តើយើងនឹងធ្វើយ៉ាងដូចម្តេចជាមួយនឹងការលំអៀងយ៉ាងច្បាស់ក្រឡែតនេះពីសំណាក់លោក លោកស្រីចៅក្រម ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលជាផលវិបាក ឬ ដែលជាការអនុវត្តគោលនយោបាយនេះ?[26]

12. អង្គជំនុំជម្រះបានច្រានចោលការជំទាស់នេះ ដោយបានសម្រេចដូចខាងក្រោម៖

អង្គជំនុំជម្រះទទួលស្គាល់ថា ឯកសារទាំងឡាយដែលភាគីអាចមានបំណងគួសបញ្ជាក់នៅក្នុងអំឡុងពេលនៃសវនាការនេះស្តីអំពីឯកសារគន្លឹះ អាចរួមមានព័ត៌មានដែលទំនងនឹងចង្អុលបង្ហាញអំពីអត្ថិភាព ឬ ការបង្កើតគោលនយោបាយ និងការអនុវត្តគោលនយោបាយនេះ។ ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះមានបំណងគួសបញ្ជាក់ថា ភាគីទាំងឡាយមានសិទ្ធិផ្តល់យោបល់លើគ្រប់ទិដ្ឋភាពនៃឯកសារដែលបានយោងនៅក្នុងអំឡុងពេលនៃសវនាការនេះ

[26] សេចក្តីព្រាងប្រតិចារឹក (ជាភាសាអង់គ្លេស) ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៦:១៧-៤៧:២២។

ពាក់ព័ន្ធនឹងភាពពាក់ព័ន្ធ នឹងតម្លៃនៃភស្តុតាង ហើយអង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចទាំងនេះនៅក្នុងពេលរៀបចំសាលក្រម។

ទោះបីជាយ៉ាងនេះក្តី វាចាំបាច់គូសបញ្ជាក់ថា សំណុំរឿង ០០២/០១ រួមទាំង គោលនយោបាយដែលមានអត្ថិភាព ឬ ដែលត្រូវបានបង្កើត ហើយការអនុវត្តគោលនយោបាយទាំងនេះក្រៅពីការជម្លៀសទីក្រុងគឺមិនពាក់ព័ន្ធទៅនឹងរឿងក្តីនោះទេ។ លោកប្រធាន ខ្ញុំគិតថា នេះជាខ្លឹមសារនៃសេចក្តីសម្រេចនេះ។ សូមអរគុណលោកប្រធាន[27]។

## IV. **ទឡ្ហីករណ៍**

## **ក. ការបំបែកកិច្ចដំណើរការនីតិវិធីមិនអាចអនុវត្តបានទេ**

13. ការឆ្លើយឆ្លងគ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ គឺជាការបង្ហាញយ៉ាងច្បាស់មួយអំពីចំណុចអាទិភាពដ៏ចម្រូងចម្រាស់មួយ ដែលការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ដែលត្រូវបានបំបែកកិច្ចដំណើរការនីតិវិធី កំពុងមានបញ្ហា។ មូលដ្ឋាននៃទ្រឹស្តីនៃការបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា មានការបែងចែកដែលអាចដំណើរការទៅបានរវាងអត្ថិភាពនៃគោលនយោបាយសហករណ៍កម្មរួម និងការអនុវត្តគោលនយោបាយទាំងនេះ ត្រូវបានបង្ហាញថាជាមូលដ្ឋានមិនត្រឹមត្រូវ។ សហព្រះរាជអាជ្ញាបានសង្ខេបបញ្ហានេះក្នុងពាក្យពេចន៍យ៉ាងពិរោះស្តាប់ថា (ហើយនៅក្នុងការសង្ខេបនេះ វាជាខ្លឹមសារសំខាន់នៃបណ្តឹងឧទ្ធរណ៍)៖ “វាមានទំនាក់ទំនងគ្នាទាំងស្រុងរវាងគោលនយោបាយ និងការអនុវត្តគោលនយោបាយនេះ”[28]។

14. ការវិវឌ្ឍទៅមុខ (ឬ ការវិវឌ្ឍថយក្រោយ) ចេញពីការលើកឡើងអំពីគោលការណ៍របស់ចៅក្រម Lavergne នៅថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣ ចំពោះសេចក្តីសម្រេចរបស់ចៅក្រម Cartwright មួយថ្ងៃក្រោយមក បានបង្ហាញថា ផ្អែកតាមការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះមិនមានលទ្ធភាពរក្សាការបែងចែកដែលអាចបើកឱ្យមានការប្តឹងសាទុក្ខផ្អែកតាមទ្រឹស្តីបានទេ។ តាមទម្ងន់នៃទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា (ដែលមានលក្ខណៈសមហេតុផលបំផុតនោះ) អង្គជំនុំជម្រះគ្មានជម្រើសអ្វីក្រៅពីអនុញ្ញាតឱ្យសហមេធាវីនាំមុខមានឱកាសគ្មានព្រំដែន ដើម្បីបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំងឡាយពាក់ព័ន្ធនឹងការចោទប្រកាន់អំពីស្ថានភាពនៅក្នុងសហករណ៍ និងទុក្ខសោក និង

---

[27] សេចក្តីព្រាងប្រតិចារឹក (អង់គ្លេស) ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៩:៣-១៦។

[28] *សូមមើល* កថាខណ្ឌ ៩ *ខាងលើ*។

ការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ[29]។ ជាការពិត ការណែនាំរបស់ចៅក្រម Lavergne ថា "ការអនុវត្តនៅមូលដ្ឋាននេះ [...] គឺមិនគួរជាផ្នែកមួយនៃការបង្ហាញឯកសារគន្លឹះដែលនាំដល់ការដកចេញនូវឯកសារអ្វីឡើយ"។

15. សេចក្តីសម្រេចរបស់ចៅក្រម Cartwright នៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ បានសម្រេចថា ភាគីនឹងមានសិទ្ធិលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួនអំពី "ភាពពាក់ព័ន្ធ និងតម្លៃជាភ័ស្តុតាង" នៃឯកសារទាំងឡាយដែលដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញ[30]។ ក៏ប៉ុន្តែ បើទោះជាអនុញ្ញាតឲ្យលើកពី "ភាពពាក់ព័ន្ធក៏ដោយ" អង្គជំនុំជម្រះបានសម្រេចម្តងហើយម្តងទៀតថា ការឆ្លើយតបទៅនឹងការបង្ហាញឯកសារនៅក្នុងពេលសវនាការគួរលើកឡើងពាក់ព័ន្ធតែអំពី "តម្លៃជាភ័ស្តុតាង" តែប៉ុណ្ណោះ ពុំមែនអំពីភាពអាចទទួលយកបានឡើយ ដែលត្រូវបានសន្មតថាបានសម្រេចរួចរាល់អស់ហើយ[31]។ នៅពេលអនុញ្ញាតឲ្យបង្ហាញឯកសារទាំងនេះ អង្គជំនុំជម្រះបានទទួលស្គាល់ថា ឯកសារទាំងនេះពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ រួចទៅហើយ ហើយទទួលស្គាល់នូវការដាក់បញ្ចូលឯកសារទាំងនេះនៅក្នុងបណ្តុំនៃភស្តុតាងដែលអង្គជំនុំជម្រះអាចយកធ្វើជាសំអាងនៅពេលចេញសាលក្រម។

16. ចំណុចបង្ហាញឲ្យឃើញមួយអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានការពាក់ព័ន្ធជាពិសេសទៅនឹងបណ្តឹងសាទុក្ខ គឺជាការបង្ហាញលម្អិតរបស់សហព្រះរាជអាជ្ញាអំពីឯកសារពាក់ព័ន្ធ នឹងមន្ទីរ ស២១។ សហព្រះរាជអាជ្ញាបានលះបង់ពេលវេលា ២ ម៉ោងពេញតែម្តង នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ ដើម្បីធ្វើបទបង្ហាញដែលរួមបញ្ចូលទាំងចម្លើយសារភាព និងការវិភាគលម្អិតអំពីការចោទប្រកាន់លើតួនាទីរបស់ នួន ជា[32]។ បើទោះជាអង្គជំនុំជម្រះនេះពិនិត្យមើលឡើងវិញនូវសេចក្តីសន្និដ្ឋានលម្អិតរបស់ភាគី និងធ្វើការប្រជុំពិភាក្សាសម្រេចថាតើមន្ទីរ ស២១ គឺជាផ្នែកមួយនៃ

---

[29] *សូមមើល* កថាខណ្ឌ ១២ *ខាងលើ*។

[30] *សូមមើល* កថាខណ្ឌ ១២ *ដូចខាងលើ*។

[31] *សូមមើល* ឧទាហរណ៍ ឯកសារលេខ E-167.1 "សារផ្ញើជូនភាគីនានាមុនពេលកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការនាព្រឹកថ្ងៃស្អែក" ចុះថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១២ ("ហេតុដូច្នេះ សវនាការដែលនឹងចាប់ផ្តើមនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២ មិនមានគោលបំណងលើកឡើងជាថ្មីនូវបញ្ហានៃភាពអាចទទួលយកបាននៃឯកសារណាមួយដែលត្រូវស្នើសុំឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះឡើយ")។

[32] សេចក្តីព្រាងប្រតិចារឹក (អង់គ្លេស) ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៤:២៥-៦៤:១២។

ការជំនុំជម្រះលើសំណុំរឿង ០០២/០១ ដែរឬទេនោះ អង្គជំនុំជម្រះសាលាដំបូង ក្នុងពេលដំណាលគ្នានេះ កំពុងបន្តពិចារណាលើភ័ស្តុតាង និងរៀបចំសម្រេចលើអង្គហេតុ។

17. សហព្រះរាជអាជ្ញាលើកឡើងថា ជនជាប់ចោទពុំដែលធ្លាប់ត្រូវបានបដិសេធឱកាសជជីកសួរអង្គហេតុពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ឡើយ[33]។ ប៉ុន្តែ ជំហរលើកឡើងនោះពុំមានមូលដ្ឋានឡើយ សូម្បីតែបន្តិចបន្តួចក៏ដោយ។ ប្រសិនបើ "អង្គហេតុនៅថ្នាក់មូលដ្ឋាន នៅថ្នាក់ក្រោមនៃឋានានុក្រម"[34] គឺជាផ្នែកមួយនៃការបង្ហាញភ័ស្តុតាងពាក់ព័ន្ធនឹងគោលនយោបាយដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ នោះអង្គជំនុំជម្រះកំពុងត្រូវបានជំរុញឲ្យសន្និដ្ឋានដោយផ្អែកលើប្រតិចារឹកដែលពុំពេញលេញ ឬគ្មានសារៈសំខាន់អ្វីដែលត្រូវចាប់ផ្ដើមបំបែកកិច្ចដំណើរការនីតិវិធីឡើយ។ ទាំងសហព្រះរាជអាជ្ញា ទាំងអង្គជំនុំជម្រះសាលាដំបូង ពុំធ្លាប់ទទួលបានជោគជ័យនៅក្នុងការពន្យល់ថាតើ "អង្គហេតុនៅមូលដ្ឋានណាខ្លះ" ដែលពាក់ព័ន្ធនឹង "អត្ថិភាព" នៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម ហើយដូច្នេះស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយអង្គហេតុណាខ្លះមិនពាក់ព័ន្ធ និងដោយសារហេតុផលអ្វី។

18. ជាការពិត ក្រុមមេធាវីការពារក្ដីយល់ស្របទាំងស្រុងថា ភ័ស្តុតាងពាក់ព័ន្ធនឹងហេតុការណ៍លម្អិតនៅតាមទីតាំងឧក្រិដ្ឋកម្មនីមួយៗអាចពាក់ព័ន្ធនឹងអត្ថិភាព (ឬ មិនមែនជាអត្ថិភាព) នៃអ្វីដែលហៅថា "គោលនយោបាយ" នោះ។ ឧទាហរណ៍ ភ័ស្តុតាងដែលបង្ហាញថា អង្គភាព ឬទីកន្លែងដូចបានរៀបរាប់ដោយសហចៅក្រមស៊ើបអង្កេតថាជា "សហករណ៍" ដែលតាមការពិតមានភាពខុសគ្នាយ៉ាងខ្លាំងទៅតាមតំបន់ទីតាំងភូមិសាស្ត្រ អាចថា គ្មានគោលនយោបាយណាមួយមានអត្ថិភាពឡើយ ឬប្រសិនបើមានអត្ថិភាពមែននោះ ការកំណត់ក្នុងគោលនយោបាយនេះពុំមានភាពច្បាស់លាស់ទេ។ ដូចគ្នានេះដែរ ការគ្មានភ័ស្តុតាងពីមេដឹកនាំសហករណ៍ថា ពួកគេបានរាយការណ៍ជាលក្ខណៈប្រព័ន្ធទៅមជ្ឈិមបក្ស ទំនងជាបង្ហាញថា ប្រសិនបើសហករណ៍ទាំងនេះមានមែននោះ សហករណ៍ទាំងនេះដំណើរការទៅដោយស្វយ័ត និងពុំអនុវត្តតាមអ្វីដែលហៅថា "គោលនយោបាយ" នោះឡើយ។ ហេតុដូច្នេះ ជាការសមស្របបំផុត ប្រសិនបើអង្គជំនុំជម្រះលើកភ័ស្តុតាងបង្ហាញអំពីសហករណ៍ ដោយដាក់

[33] *សូមមើល* កថាខណ្ឌ ៥ខាងលើ។

[34] *សូមមើល* កថាខណ្ឌ ៩ *ខាងលើ*។

ភ័ស្តុតាងទាំងនោះឲ្យមានការដេញដោលតទល់គ្នា និងធ្វើការសម្រេចដោយផ្អែកលើភ័ស្តុតាងនោះ ពាក់ព័ន្ធនឹងការចោទប្រកាន់លើ "គោលនយោបាយ" សហករណ៍នៃបក្សកម្មុយនីស្តកម្ពុជា។

19. ជម្រើសមួយទៀត អង្គជំនុំជម្រះគួរតែបានសម្រេចថា អត្ថិភាពនៃគោលនយោបាយសហករណ៍អាច បង្ហាញត្រឹមតែតាមរយៈភ័ស្តុតាងផ្ទាល់ពីសំណុំអង្គហេតុដែលមានកម្រិតទាបបំផុត ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសេចក្តីសម្រេច និងការប្រព្រឹត្ត ពោលគឺ តាមពាក្យពេចន៍សាមញ្ញ សំដៅលើ "គោលនយោបាយ" របស់មជ្ឈិមបក្ស។ អង្គជំនុំជម្រះក៏អាចសម្រេចថា "គោលនយោបាយ" នៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ មិនមែនជាបញ្ហាចោទសម្រាប់ការជំនុំជម្រះនាពេលបច្ចុប្បន្នឡើយ។

20. ទោះបីជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនអាចសម្រេចមិនកោះហៅសាក្សីឡើយ ហើយក៏មិនអាចហាមឃាត់ភាគីមិនឲ្យពិនិត្យដេញដោលសាក្សីដែលត្រូវបានកោះហៅមកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹង "អង្គហេតុនៅមូលដ្ឋាននេះ"ដែរ រួចហើយផ្អែកលើភ័ស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយគ្មានគោលបំណងច្បាស់លាស់ និងដោយប្រថុយប្រថាន[35] ដើម្បីធ្វើសេចក្តីសន្និដ្ឋានទាំងមូលអំពី "គោលនយោបាយ" ដែលបានបង្កើតឡើងដោយបក្សកម្មុយនីស្តកម្ពុជាឡើយ។

## ខ. សិទ្ធិជាមូលដ្ឋានរបស់ នួន ជា ប្រឈមនឹងហានិភ័យ

21. តាមរយៈកិច្ចដំណើរការនីតិវិធីនៅក្នុងលក្ខណៈបែបនេះ អង្គជំនុំជម្រះសាលាដំបូងនឹងរំលោភសិទ្ធិជាមូលដ្ឋានជាច្រើនក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ជាដំបូង ការសម្រេចលើផ្នែកអង្គហេតុពាក់ព័ន្ធនឹងអត្ថិភាពនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ០០២/០១ នឹងរំលោភសិទ្ធិរបស់ នួន ជា នៅក្នុងការតទល់នឹងភ័ស្តុតាងប្រឆាំងនឹងខ្លួនក្នុងមួយដែលថា ការសម្រេចនេះបានផ្អែកលើភ័ស្តុតាង "អង្គហេតុនៅមូលដ្ឋាន"[36]។ ដោយហេតុថា អង្គហេតុទាំងនេះមិនត្រូវបានដាក់បញ្ចូលជាលក្ខណៈប្រព័ន្ធចេញពីវិសាលភាពនៃការពិនិត្យដេញដោលរបស់ក្រុមមេធាវីការពារក្តីលើសាក្សីមកផ្តល់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះ "ភ័ស្តុតាង" ដែលជាភាពយន្តឯកសារដែលពុំបានទទួលការពិនិត្យនៅឡើយ មិនអាចបង្កើតជាមូលដ្ឋាននៃសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះបានឡើយ។

---

[35] *សូមមើល* កថាខណ្ឌ ៧ *ខាងលើ*។

[36] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១ ដល់ ១៩។

22. ចំណុចទីពីរ សេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះនេះដោយផ្អែកលើភ័ស្ដុតាងខ្លះអាចបង្កើតជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានផ្នែកអង្គហេតុពាក់ព័ន្ធនឹងគោលនយោបាយ ដែលជាបញ្ហាចោទនៅក្នុង សំណុំរឿង ០០២/០២ ហើយនឹងធ្វើឱ្យអង្គជំនុំជម្រះនេះមានភាពលំអៀងនៅក្នុងការវិនិច្ឆ័យលើការជំនុំជម្រះលើកទីពីរ[37]។ ការចោទប្រកាន់ពាក់ព័ន្ធនឹងគោលនយោបាយបក្សកម្មុយនីស្តកម្ពុជាទាក់ទិននឹងសហករណ៍ និងការដ្ឋានការងារ ការចេញបទបញ្ជានៃការរៀបការ មន្ទីរសន្តិសុខ និងការកំណត់គោលដៅក្រុមនានាក្រៅពីអតីតទាហាន និងមន្ត្រីនៃរបបសាធារណៈរដ្ឋខ្មែរ នឹងមានសារៈសំខាន់ជាចំបងនៅក្នុងការជំនុំជម្រះវគ្គក្រោយៗ។ ក្រោយពីបានធ្វើសេចក្ដីសន្និដ្ឋានលើករណីនេះនៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងនឹងពុំមានលទ្ធភាពវិនិច្ឆ័យដោយយុត្តិធម៌លើបញ្ហាចោទទាំងឡាយសារជាថ្មីម្ដងទៀតនៅក្នុងសំណុំរឿង ០០២/០២ ឡើយ។

23. ចំណុចទីបី យើងឃើញមានការបន្តការរំលោភលើសិទ្ធិទទួលបានសច្ចៈភាពផ្លូវច្បាប់របស់ភាគីទាំងអស់។ សារណាបញ្ចប់ការពិភាក្សាដេញដោលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូងប្រហែលជាក្នុងរយៈពេល ២ ខែ ទៀត[38]។ អង្គជំនុំជម្រះបានបញ្ជាក់ថា នៅត្រឹមពេលបញ្ចប់ការជំនុំជម្រះ តាមការរំពឹងទុក ឯកសារជាង ៦.០០០ ឯកសារនឹងមានជាភ័ស្ដុតាង[39]។ ប៉ុន្តែ គ្មានភាគីណាមួយដឹងច្បាស់ថាតើឯកសារទាំងនេះដែលពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងត្រូវបានប្រើប្រាស់ដោយរបៀបណា។ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅអឡុងពេលសវនាការលើឯកសារនាំទៅដល់ "ការបញ្ចូលនូវអង្គហេតុថ្មី និង កាលៈទេសៈទៅនឹងប្រធានបទរបស់សវនាការ [ដែល] នឹងធ្វើឱ្យផ្លាស់ប្ដូរវិសាលភាពគន្លិះនៃសវនាការ"[40]។ ប្រការនេះមិនឆ្លើយតបទៅនឹងសិទ្ធិរបស់ជនជាប់ចោទក្នុងការ "ទទួលបានការជូនដំណឹងទាន់ពេល និង ភាពលម្អិត មូលហេតុ និងបទចោទ"

---

[37] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២១។

[38] ឯកសារលេខ E-1/207.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ៤៨:១៩-២២។

[39] ឯកសារលេខ E-1/207.1 "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ ទំព័រ ២៦:៣-២០។

[40] *Prosecutor v. Lubanga* "សាលដីកាលើបណ្ដឹងឧទ្ធរណ៍លោក Lubanga Dyilo និង សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះទី១ នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៩ " សេចក្ដីសម្រេចផ្ដល់ការជូនដំបូងដល់ភាគី និង អ្នកចូលរួមថាលក្ខណៈច្បាប់នៃអង្គសេចក្ដីអាចផ្លាស់ប្ដូរដោយអនុលោមតាមវិធាន ៥៥(២) នៃវិធានផ្ទៃក្នុងតុលាការ"" ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩ ("សេចក្ដីសម្រេច *Lubanga*)" កថាខណ្ឌ ៨៥។

[និង] ដើម្បីទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការពារក្តី""[41]។ លទ្ធភាពរបស់ភាគីក្នុងការវាយតម្លៃលើភាពចាំបាច់ក្នុងការតវ៉ាលើខ្លឹមសារនៃភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះត្រូវបានប៉ះពាល់។ ពេល វេលារៀបចំដ៏សំខាន់ពាក់ព័ន្ធនឹងសារណាបញ្ចប់ការពិភាក្សាដេញដោលបានបន្តខាតបង់ជារៀងរាល់ថ្ងៃ។

24. ចំណុចចុងក្រោយ ក្រុមមេធាវីការពារក្តីកត់សម្គាល់ឃើញថា យោងតាមសហព្រះរាជអាជ្ញា ក្រុមមេធាវីការពារក្តី នួន ជា ធ្លាប់បានបណ្តោយឲ្យអង្គជំនុំជម្រះប្រើប្រាស់ភ័ស្តុតាងដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ក្នុងគោលបំណងបង្ហាញឲ្យឃើញអត្ថិភាពគោលនយោបាយទាំង ៥ ដែលបានចោទប្រកាន់លើរបបកម្ពុជាប្រជាធិបតេយ្យ[42]។ ការអះអាងនេះមិនត្រឹមត្រូវឡើយ។ ក្រុមមេធាវីការពារក្តីបានយល់ស្របលើកមុនជាមួយនឹងសញ្ញាណដែលមានការឯកភាពគ្នាថា "ប្រសិនបើមានភ័ស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះ មានការពាក់ព័ន្ធនឹងការសម្លាប់នៅមន្ទីរ ស២១ និងនៅស្រុក ១២ " ភ័ស្តុតាងទាំងនោះអាចត្រូវបានប្រើប្រាស់ ដើម្បីបង្ហាញអំពី "ការបង្កើតគោលនយោបាយឧក្រិដ្ឋទាំង ៥ ដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ"[43]។ វាកម្រនឹងមានបញ្ហាចោទថា ភ័ស្តុតាងអំពីមូលដ្ឋាននៃបទល្មើស "អាចត្រូវបាន" ប្រើប្រាស់ពាក់ព័ន្ធនឹងគោលនយោបាយទាំងឡាយដូចដែលបានចោទប្រកាន់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ (*សូមមើល* កថាខណ្ឌ ១៨ *ខាងលើ*)។ ប៉ុន្តែ ក្រុមមេធាវីការពារក្តីពុំដែលយល់ស្របថា ភ័ស្តុតាងបែបនេះមានអត្ថិភាពឡើយ។ ជាការពិតណាស់ថា ប្រសិនបើភ័ស្តុតាងទាំងនេះត្រូវបានយកមកប្រើប្រាស់មែននោះ ជាដំបូង ភស្តុតាងទាំងនេះត្រូវតែមានការទទួលយកក្នុងលក្ខណៈមួយស្របជាមួយនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ដោយសារតែការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងចំណុចនេះ ទើបធ្វើឲ្យមានការជំទាស់ភ្លាមៗបែបនេះ។

25. យោងតាមហេតុផលទាំងនេះ ក្រុមមេធាវីការពារក្តីសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលសុំឲ្យ៖

ក. **ទទួលយក** សារណាបន្ថែមនេះ និង

---

[41] សេចក្តីសម្រេច *Lubanga* កថាខណ្ឌ ៨៥។

[42] ចម្លើយតប កថាខណ្ឌ ១០។

[43] ចម្លើយតប កថាខណ្ឌ ១០។

ខ. **ពិចារណា** លើសារណាបន្ថែមលើកទីពីរនេះរួមជាមួយនឹងបណ្តឹងសាទុក្ខ។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE